# ពិធីការជំងឺឆ្កែឆ្កួត

## ការគ្រប់គ្រងសត្វឆ្កែ និងឆ្មាប៉ះពាល់នឹងសត្វព្រៃ

### និយមន័យ

1. ការដាក់ឱ្យនៅដាច់ដោយឡែក
   a) ការដាក់កម្រិតសត្វក្នុងស្រុក ពីការប៉ះពាល់ផ្ទាល់ដោយមនុស្ស ឬសត្វដទៃទៀត។
   b) សត្វត្រូវតែបង្ខាំងនៅក្នុងកន្លែងដូចជា ទ្រុងឆ្កែ មន្ទីរពេទ្យបសុពេទ្យ កន្លែងលក់សត្វ ឬកន្លែងដាក់ឱ្យនៅដាច់ពីគេ សម្រាប់សត្វចិញ្ចឹមដែលត្រូវបានអនុម័តដោយ អ្នកត្រួតពិនិត្យសត្វរបស់ក្រុងដែលសមស្រប ឬនៅដាច់ដោយឡែកនៅផ្ទះ ក្រោមលក្ខខណ្ឌដែលត្រូវបានអនុម័តដោយអធិការសត្វក្នុងក្រុងនិងនាយកដ្ឋាន។
2. ការឃុំឃាំងអោយតឹងរ៉ឹង
   a) សត្វអាចត្រូវបានរក្សាទុកនៅផ្ទះដែលមានការការពារមិនអោយរត់ចេញ នៅក្នុងអគារដែលមានជញ្ជាំងរឹងមាំ ដែលមានដំបូល ដែលត្រូវបានអនុម័តដោយ អ្នកត្រួតពិនិត្យសត្វរបស់ក្រុង។
   b) សត្វអាចត្រូវបានចងខ្សែរដើរដោយមនុស្សធំ ឬស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មនុស្សពេញវ័យ។
   c) ម្ចាស់បានជូនដំណឹងអំពីហានិភ័យដែលអាចកើតមានជំងឺឆ្កែឆ្កួត និងការណែនាំជាលាយលក្ខណ៍អក្សរ។
   d) ម្ចាស់តម្រូវឱ្យជូនដំណឹងទៅពេទ្យសត្វ និងអ្នកត្រួតពិនិត្យសត្វអំពីអាកប្បកិរិយាមិនធម្មតា ឬការផ្លាស់ប្តូរស្ថានភាពសុខភាពរបស់សត្វចិញ្ចឹម។
3. ការប៉ះពាល់ដោយនៅជិត - ឃើញនៅជិត ឬក្បែរសត្វដែលបានបញ្ជាក់ថាមានជំងឺឆ្កែឆ្កួត ប៉ុន្តែមិនមានការប៉ះពាល់លើរាងកាយ ឬមិនបានបង្ករបួសពីសត្វដែលមានជំងឺឆ្កែឆ្កួតនោះទេ។
4. ការដាក់ឱ្យនៅដាច់ពីគេ - ការបង្ខាំងសត្វក្នុងផ្ទះពីមនុស្ស និងសត្វដទៃទៀត ក្នុងគោលបំណងសង្កេតមើលសត្វ ដើម្បីរកសញ្ញាជំងឺឆ្កែឆ្កួត និងកាត់បន្ថយឱកាសដែលសត្វនេះនឹងរីករាលដាលជំងឺឆ្កែឆ្កួតទៅកាន់មនុស្ស ឬសត្វដទៃទៀត។ នេះរួមបញ្ចូលទាំងដាក់អោយនៅដាច់ដោយឡែកនិងឃុំឃាំងអោយបានតឹងរ៉ឹង។
5. រោគសញ្ញាជំងឺឆ្កែឆ្កួត - ឆេវឆាវដែលមិនអាចពន្យល់បាន ការចុះខ្សោយចលនា គាំងផ្សេងៗគ្នាមានការតឹងតែងខ្លាំង ឬកាចសាហាវ។ រោគសញ្ញាជំងឺឆ្កែឆ្កួតមានភាពខុសគ្នានៅក្នុងសត្វ។ សត្វខ្លះនឹងបង្ហាញអាកប្បកិរិយា ដូចការវាយប្រហារ ខណៈពេលដែលសត្វផ្សេងទៀតហាក់ដូចជាឈឺ ឬវង្វេង។
6. សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកត្រួតពិនិត្យសត្វក្នុងទីក្រុង/ក្រុងរបស់អ្នក។